**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

# កំណត់ហេតុ
## កិច្ចប្រជុំពិភាក្សា ស្តីពី ករណីស្រ្តីពពោះជំនួស

ឆ្នាំពីរពាន់ម្ភៃពីរ ខែមេសា ថ្ងៃទីប្រាំ វេលាម៉ោងដប់បួន និងសូន្យនាទី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី ករណីស្រ្តីពពោះជំនួស តាមប្រព័ន្ធប្រជុំអនឡាញ (Zoom) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានសមាសភាពចូលរួមចំនួន ១៣រូបៈ

១. **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
២. **ឯកឧត្តម តាំង ស៊ុនឡាយ** ប្រធានសាលាដំបូងរាជធានីភ្នំពេញ
៣. **លោក គីម ហុងសាន** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តំណាងឱ្យ **ឯកឧត្តម ច្រឹង ខ្មៅ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូរាជធានីភ្នំពេញ
៤. **ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៥. **ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៥. **លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៦. **ឯកឧត្តម ឧត្តមសេនីយ៍ទោ តែ សុថារ៉េត** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៧. **ឯកឧត្តម ឧត្តមសេនីយ៍ទោ នី គីមស្រេន** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៨. **ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
៩. **លោកស្រី ព្រុំ សុខន** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
១០. **លោក ឧត្តមសេនីយ៍ទោ ហាង ជីវ័ន្ត** ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
១១. **លោក ឧត្តមសេនីយ៍ទោ កែវ ផល្លា** ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
១១. **លោក ឧ.ទោ សេក ស៊ីវ៉េត** ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
១២. **លោក វរសេនីយ៍ឯក លៅ លីន** អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១៣. **លោកអនុសេនីយ៍ឯក វ៉ន សុភ័ក្រ្តបញ្ញា** នាយរងការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានមតិស្វាគមន៍ និងបើកកិច្ចប្រជុំ។ នៅក្នុងឱកាសសំណេះសំណាល លោកជំទាវបានធ្វើការរំឭកពី ប្រវត្តិនៃរឿងរ៉ាវក្នុងករណីស្រ្តីពពោះចំនួន០២នាក់ ដែលត្រូវបានសមត្ថកិច្ចវៀតណាម ឃាត់ខ្លួននិងបញ្ជូនត្រឡប់មកកម្ពុជាវិញ។ ស្រ្តីទាំងពីរនាក់រួមមាន ១. ឈ្មោះ សន ស្រីនួ កើតថ្ងៃទី ០៧-០៣-១៩៩៥ ខេត្តតាកែវ និង ២. ឈ្មោះ ប៉ុល ស្រី កើតថ្ងៃទី ១៧-០៥-១៩៩២ ខេត្តស្វាយរៀង។ ប៉ុន្តែបន្ទាប់ពីក្រុមការងារនៃមន្ទីរសង្គមកិច្ច បានធ្វើការសាកសួរបន្ថែម យើងបានរកឃើញថា ឈ្មោះពិតរបស់ស្រ្តីទាំង០២នាក់នោះគឺ ឈ្មោះ ឯម រស្មី (សន ស្រីនួ) និងឈ្មោះ ប៊ុន បៃ (ប៉ុល ស្រី)។ ស្រ្តីទាំង០២នាក់នោះបានត្រូវរក្សាសុខភាពនៅមន្ទីរពេទ្យ ១៦ឧសភា និងក្រោយមកបានសម្រាលកូន (ភ្លោះ) ទាំងពីរនាក់នៅមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក។ ឥឡូវនេះលោកជំទាវយល់ថា វាគួរដល់ពេលដែលយើងត្រូវ

ពិភាក្សាគ្នា ថាតើត្រូវបន្តនីតិវិធីបន្តទៀតដោយរបៀបណា ព្រោះថាយើងធ្លាប់មានបទពិសោធន៍កន្លងមករួមមកហើយក្នុងករណីស្រដៀងគ្នានេះដែរ ដោយមានស្ត្រីពពោះចំនួន ១១នាក់ ដែលត្រូវបានអាជ្ញាធរវៀតណាមបញ្ជូនមក ហើយយើងបានយកមកអនុវត្តទោសរហូតដល់មានខ្លះត្រូវបានដាក់ពន្ធនាគារទៀតផង។ ដូច្នេះយើងមិនអាចធ្វើឲ្យករណីនេះមានការអនុវត្តខុសគ្នាឡើយ។

**លោកវរសេនីយ៍ឯក លៅ លីន** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើសេចក្តីរាយការណ៍បន្ថែមពាក់ព័ន្ធនឹងករណីនេះថា បន្ទាប់ពីទទួលបានដំណឹងអំពីករណីនេះ នាយកដ្ឋានបានសហការណ៍ជាមួយនឹងមន្ទីរសង្គមកិច្ច ធ្វើការស្រាវជ្រាវរកឃើញថា ស្ត្រីទាំង០២នាក់នេះគឺពិតបានប្តូរឈ្មោះពិតប្រាកដមែន ហើយដាក់ស្តែងឈ្មោះ សន ស្រីនូ ត្រូវបានអាជ្ញាធរមូលដ្ឋានបញ្ជាក់មកថា ឈ្មោះនេះបានចាកចេញពីលំនៅដ្ឋានមកធ្វើការរោងចក្រ នៅរាជធានីភ្នំពេញយូរមកហើយ។ តាមរយៈការស្រាវជ្រាវ យើងបានរកឃើញតម្រុយថា មានស្ត្រីឈ្មោះ ស្រីពៅ បានមកទំនាក់ទំនង ស្ត្រីទាំង០២នាក់ខាងលើនេះឲ្យពពោះជំនួសដោយបានប្រាប់ថា នឹងទទួលបានលុយក្នុងម្នាក់៨៥០០ដុល្លារអាមេរិក ទើបស្ត្រីទាំងពីរអ្នកនេះយល់ព្រម។ បន្ទាប់មកយើងក៏បានរកឃើញទីតាំងដែលស្ត្រីទាំង០២នាក់បានទៅទទួលការចាក់បញ្ចូលមេជីវិត ហើយបច្ចុប្បន្នសមត្ថកិច្ចយើងកំពុងធ្វើការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ ដោយមានការណែនាំពីលោកព្រះរាជអាជ្ញាផងដែរ ប៉ុន្តែពុំទាន់មានសភាពការអ្វីដែលគួរឲ្យកត់សម្គាល់នៅឡើយទេ។ ស្ត្រីទាំងពីរអ្នកនោះរហូតមកទល់ពេលនេះ គឺបានទទួលលុយមួយចំនួនរួចហើយ គឺឈ្មោះ សន ស្រីនូ (ឯម រស្មី) ទទួលបានសរុបចំនួន ២៤០០ដុល្លារអាមេរិក ហើយឈ្មោះ ប៉ុល ស្រី (ប៊ុន បៃ) ទទួលបាន ១៥៦០ដុល្លារ។ តាមរយៈការឆែកប្រវត្តិប្រើប្រាស់លេខទូរស័ព្ទទំនាក់ទនង យើងរកឃើញលេខដែលគួរឲ្យសង្ស័យ ដែលមានឈ្មោះថា ស្រីអូន មានទីតាំងប្រើប្រាស់នៅសង្កាត់ផ្សារដេប៉ូ១ ប៉ុន្តែអាជ្ញាធរនៅមូលដ្ឋាននោះបានបញ្ជាក់ថា ពុំមានឈ្មោះនេះនៅក្នុងមូលដ្ឋានទេ ដូច្នេះទិសដៅបន្តគឺសុំកិច្ចសហការជាមួយអត្តសញ្ញាណកម្មដើម្បីស្វែងរកអត្តសញ្ញាណពិតប្រាកដរបស់ឈ្មោះ ស្រីអូន នេះជាបន្តទៀត។ នាយកដ្ឋាននឹងធ្វើការសម្ភាសន៍ដោយផ្ទាល់ជាមួយស្ត្រីទាំង០២នាក់បន្ថែមទៀតដើម្បីស្រាវជ្រាវរកតម្រុយបន្ថែមទៀត។

**លោកជំនាវ អនុប្រធានអចិន្ត្រៃយ៍** ក៏បានគូសបញ្ជាក់បន្ថែមថា តាមរយៈរបាយការណ៍នេះ យើងគួរចាប់អារម្មណ៍ថា ស្ត្រីដែលពពោះជំនួសភាគច្រើនគឺមានប្រភពចេញមកពី កម្មកររោងចក្រកាត់ដេរ ដូច្នេះមានន័យថាស្ត្រីនៅរោងចក្រភាគច្រើនទទួលបានការផ្សព្វផ្សាយនូវព័ត៌មានស្តីពីការពពោះជំនួសនេះ។ ដូច្នេះមានន័យថាមានស្ត្រីជាច្រើនអ្នកមកហើយដែលបានធ្វើរឿងនេះ ហើយវាក៏នៅកំពុងតែបន្តកើតឡើង។ កន្លងមកយើងធ្លាប់បានរៀបចំធ្វើច្បាប់ស្តីពីការពពោះជំនួស ប៉ុន្តែយើងសង្កេតឃើញថាខ្លឹមសារនៃច្បាប់នេះគឺផ្តោតតែលើ របៀបនៃការពពោះជំនួស ដោយពុំបានសង្កត់ធ្ងន់លើទោសទណ្ឌនៃការពពោះជំនួស ទើបធ្វើឲ្យមានការផ្អាកការធ្វើសេចក្តីព្រៀងច្បាប់នេះវិញ។ អញ្ចឹងការអនុវត្តកន្លងមក គឺយើងប្រើប្រាស់ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានការនាំអនីតិជនចេញដោយមិនស្របច្បាប់ជាដើម។ ប៉ុន្តែទោះជាយ៉ាងនេះក្តីយើងឃើញថា ករណីពពោះជំនួសនេះ ហាក់ពុំមានការស្ងប់ស្ងាត់ឡើយ ដូច្នេះបើយើងព្រងើយកន្តើយក្នុងរឿងនេះ រដ្ឋាភិបាលនឹងក្លាយជាអ្នកទទួលបន្ទុកប៉ះរងជំនួសជនល្មើស ជនល្មើសនៅតែរួចខ្លួន និងបន្តសកម្មភាពល្មើស ហើយសង្គមកម្ពុជាជួបមហន្តរាយធំដល់ទារករបស់យើងនៅថ្ងៃអនាគតជាពុំខាន។ ជាការពិតស្ត្រីដែលបានពពោះជំនួសតែងតែនិយាយថា ខ្លួនធ្វើបែបនេះដោយសារតែជីវភាពក្រីក្រ ប៉ុន្តែយើងពុំអនុញ្ញាតឲ្យជនណាម្នាក់ជាពិសេសស្ត្រីដែលជាម្តាយទារកក្នុងផ្ទៃ ប្រព្រឹត្តបទល្មើសដើម្បីដោះស្រាយជីវភាពរបស់ខ្លួនឡើយ។ ម៉្យាងទៀត អង្គការសហប្រជាជាតិ តែងតែជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់គោរពសិទ្ធិមនុស្សជាពិសេសស្ត្រី ប៉ុន្តែពួកគេមិនដែលយកចិត្តទុកដាក់ថា រឿងនេះគឺជារឿងជួញដូរមនុស្សឡើយ។

**លោកជំទាវ ឧត្តមសេនីយ៍ឯក ទេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមមតិយោបល់ផងដែរថា កន្លងមកក្នុងការថែទាំសុខភាពរបស់ស្ត្រីទាំងពីរនាក់ខាងលើនេះ នៅមន្ទីរពេទ្យ១៦ ឧសភា គឺខាងមន្ទីរពេទ្យយើងបានយកចិត្តទុកដាក់ក្នុងការពិនិត្យនិងថែទាំសុខភាពជូនពួកគាត់ទាំងម្ដាយ និងទារក ប៉ុន្តែស្ត្រីទាំងនោះបានសួរទៅកាន់អង្គការដៃគូដែលបានឧបត្ថមគាំទ្រទៅពួកគាត់ថា តើពួកគាត់ខុសអ្វី? ហេតុអ្វីបានជាយកពួកគាត់ទៅសម្រាកថែទាំសុខភាពនៅក្នុងមន្ទីរពេទ្យ ប៉ុន្តែបែរជាចាក់សោរទ្វារ ហាមឃាត់មិនឱ្យពួកគាត់ចេញទៅក្រៅបាន។ ដូច្នេះក៏មានសំណួរមកកាន់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថា តើនៅពេលណាទើបយើងអាចដឹងថាពួកគាត់ទាំង០២នាក់ជាជនរងគ្រោះ ឬជាជនល្មើស?

**លោកស្រី ព្រំ សុខន** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានឆ្លើយតបផងដែរថា លោកស្រីយល់ស្របទាំងស្រុងទៅនឹងអ្វីដែលលោកជំទាវអនុប្រធានអចិន្ត្រៃយ៍បានលើកឡើង ក៏ដូចជារបាយការណ៍របស់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ លោកស្រីបានគូសបញ្ជាក់ថា សម្រាប់ខាងសង្គមកិច្ច គឺរង់ចាំការកាត់សេចក្ដីពីខាងតុលាការថា តើស្ត្រីទាំង០២នាក់នេះ ជាជនរងគ្រោះ ឬជាជនល្មើស ទើបអាចមានជាវិធានការបន្តទៅទៀតបាន។

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** បានចូលរួមបន្តទៀតថា តាមព័ត៌មានដែលទទួលបាន ទារកភ្លោះទាំង០៤នាក់ គឺត្រូវធ្វើសំបុត្រកំណើត ដូច្នេះខាងមន្ទីរពេទ្យបានចុះព័ត៌មានក្នុងលិខិតបញ្ជាក់កំណើតរបស់ពេទ្យថា ជាកូនរបស់ស្ត្រីពពោះជំនួស ប៉ុន្តែដោយតែវាជះឥទ្ធិពលខ្លាំងដល់អនាគតរបស់ទារកទាំងនោះ យើងក៏បានស្នើសុំប្ដូរទៅជាកូនរបស់ស្ត្រីមេផ្ទះ ដែលឪពុកពុំមានអត្តសញ្ញាណ។ តាមសម្ដីរបស់ប្ដីស្ត្រីដែលពពោះជំនួសទាំង០២នាក់ គឺមិនមានចេតនាចង់ចិញ្ចឹមទារកទាំងនេះទេ នេះមានន័យថា បើយើងបន្ធូរបន្ថយទោស ដោយគ្រាន់តែឱ្យពួកគេទទួលខុសត្រូវចិញ្ចឹមកូនទាំងនេះ នោះនឹងមានរឿងលួចលក់កូនទាំងនេះនៅថ្ងៃក្រោយ ដូចករណីមុនៗនេះដែរ។ ដូច្នេះយើងមិនអាចអនុគ្រោះឱ្យបានទេ ហើយខាងសង្គមកិច្ចគឺត្រូវត្រៀមខ្លួនក្នុងការធ្វើជាអាណាព្យាបាលរបស់ទារកទាំងនេះតាមនីតិវិធីច្បាប់។

**ឯកឧត្តម តាំង ស៊ុនឡាយ** ប្រធានសាលាដំបូងរាជធានីភ្នំពេញ បានលើកឡើងថា ឯកឧត្តមគាំទ្រក្នុងការដាក់ទោសស្ត្រីពពោះជំនួសទាំងនេះ ប៉ុន្តែបើយើងពិនិត្យទៅឃើញថាវាជាករណីស្រដៀងនឹងករណីកន្លងមក។ ប្រសិនបើយើងអនុវត្តតាមច្បាប់ ទោសនេះគឺជាទោសធ្ងន់ធ្ងរ ដែលអាចត្រូវបានផ្ដន្ទាទោសរហូតដល់ ១៥ឆ្នាំ ប៉ុន្តែកន្លងមកដោយយល់ថាពួកគាត់មានជីវភាពលំបាក និងមិនបានដឹងថារឿងនេះគឺជារឿងខុសច្បាប់ ទើបយើងមានការបន្ធូរបន្ថយ។ ក្នុងករណីនេះ តាមច្បាប់កូនដែលកើតចេញពីផ្ទៃរបស់ស្ត្រីទាំង០២នាក់នោះ គឺជាកូនរបស់គាត់ស្របច្បាប់ ហើយយើងអាចធ្វើសំបុត្រកំណើតឱ្យទារកទាំងនោះបាន យើងស្ត្រីនោះត្រូវទទួលចិញ្ចឹមកូននោះ ប្រសិនបើគាត់មិនទទួលចិញ្ចឹម គឺគាត់ត្រូវមានទោសផ្សេងទៀតពាក់ព័ន្ធនឹងការបោះបង់ចោលអនីតិជន។ ប្រសិនបើយើងគិតថា មុននឹងក្រោយពួកគាត់នឹងបោះបង់កូនទាំងនេះ យើងអាចគិតគូទៅលើការយកកូនទាំងនេះទៅមណ្ឌលកុមារកំព្រា ឬប្រគល់ជូនខាងសង្គមកិច្ច ប៉ុន្តែត្រូវមានការសម្រេចមួយពីតុលាការ ដើម្បីស្នើសុំទៅខាងមន្ទីរសង្គមកិច្ចដើម្បីមើលថែទាំទារកនោះ។ តាមយោបល់របស់ឯកឧត្តម ករណីនេះគួរអនុវត្តដូចករណីមុនៗដែរ ព្រោះបើយើងអនុវត្តតាមច្បាប់គឺមានលក្ខណៈតឹងរឹងខ្លាំងពេក សម្រាប់ស្ត្រីទាំង០២នេះ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានចូលរួមមតិយោបល់ក្នុងកិច្ចប្រជុំនេះផងដែរថា ខាងនាយកដ្ឋានគឺបានរៀបចំកសាងនិងបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញា ដើម្បីដាក់ការចោទប្រកាន់ហើយ ប៉ុន្តែយើងកំពុងព្យាយាមសុំឱ្យស្ត្រីដែលកំពុងតែជាប់ការសង្ស័យថាជាជន

ប្រព្រឹត្ត បទល្មើសផ្តល់ការសហការបន្ថែមទៀត ហើយយើងក៏បាននឹងកំពុងតែស្នើសុំកិច្ចសហការពីខាងអត្តសញ្ញាណកម្ម ដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យជាមេខ្យល់បន្ថែមទៀតផងដែរ។ ដូច្នេះយើងនឹងព្យាយាមពន្លឿននីតិវិធីនេះឱ្យបានឆាប់ៗ។

**លោក គឹម ហុងសាន** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក៏បានចូលរួមផងដែរថា លោកសូមគាំទ្រនូវមតិយោបល់ទាំងអស់ដែលបានលើកឡើងខាងលើ ប៉ុន្តែតាមការយល់ឃើញរបស់លោកផ្ទាល់ ករណីនេះបើយើងមានការលើកលែង ឬបន្ធូរបន្ថយដូចករណីមុនៗ នោះជនប្រព្រឹត្តបទល្មើសនឹងកាន់តែបានចិត្ត ជាហេតុធ្វើឱ្យបទល្មើសនេះនឹងកាន់តែរីករាលដាលធំឡើង ក្លាយជាវិបត្តិសង្គម។ ដូច្នេះយើងត្រូវប្រើច្បាប់ជួញដូរដើម្បីដោះស្រាយករណីនេះ ហើយលោកគាំទ្រឱ្យជំរុញ ការបង្កើតច្បាប់ប្រឆាំងការពពោះជំនួស ឱ្យបានឆាប់ផងដែរ។

នៅទីបញ្ចប់នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើការបូកសរុបកិច្ចប្រជុំថា សម្រាប់ករណីនេះយើងនឹងអនុវត្តតាមនីតិវិធីច្បាប់ ដោយគ្រាន់តែរិះរកមធ្យោបាយដើម្បីបានសម្រាលទោសខ្លះដើម្បីជាការធ្វើសារព្រមានដល់សារធារណៈជនថា ការពពោះជំនួសក្នុងគោលបំណងជួញដូរទារក គឺជាអំពើខុសច្បាប់ដែលមិនអាចអត់ឱនឱ្យបាន ហើយត្រូវតែមានការស្រាវជ្រាវដើម្បីរកមុខបណ្តាញរបស់វា និងបានផ្តាំផ្ញើថា លោកជំទាវមានសង្ឃឹមយ៉ាងមុតមាំថាគ្រប់ភាគីពាក់ព័ន្ធនឹងបន្តពង្រឹងកិច្ចសហការគ្នាឱ្យបានកាន់តែល្អ ព្រោះថារឿង ពពោះជំនួស នេះគឺកំពុងតែស្ថិតនៅក្នុងការចាប់អារម្មណ៍របស់សហគមន៍អន្តរជាតិ ក៏ដូចជាបណ្តាញអ្នកសារព័ត៌មាន អំពីវិធានការនិងគោលជំហររបស់កម្ពុជា ដូច្នេះយើងត្រូវឈរលើគោលការណ៍និងគោលជំហរមួយដូចគ្នា ជៀសវាងមានការយល់ឃើញខុសគ្នា ធ្វើឱ្យគេវាយតម្លៃមកលើរាជរដ្ឋាភិបាល។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំ និងហាសិបនាទី ថ្ងៃដដែល ប្រកបដោយលទ្ធផលជាវិជ្ជមាន ក្នុងបរិយាកាសស្និទ្ធស្នាលក្រៃលែង។

ថ្ងៃ..................ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ.........ឆ្នាំ២០២២

**លេខាកត់ត្រា**

គោរពជូន
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ...ចន្ទ ១០ កើត...ខែ.....ចេត្រ.....ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី...១១... ខែ...មេសា... ឆ្នាំ២០២២

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់

បានពិនិត្យ
11/04/22

ឧបសម្ព័ន្ធ១

## រូបថតសកម្មភាពកិច្ចប្រជុំពិភាក្សា
## ករណីស្ត្រីពពោះជំនួស




Taing Sunlay
Sotharet TE-NCCT
Sek Siveth NCCT
Yem Channarom
ny kimsren
iPhone 13 Pro Max